**១**.គណនា $\sqrt{2022+2021\sqrt{2022+2021\sqrt{2022+2021\sqrt{\dots}}}}$។

A. $\sqrt{2021}$ B. 2020 C. 2021 D. 2022 E. ចម្លើយផ្សេង

**២**. តុក្កតាខ្លាឃ្មុំដ៏ស្រស់ស្អាតមួយបានឡើងថ្លៃ20%នៅថ្ងៃឆ្លងឆ្នាំសកល។ តែក្រោយមកដោយលក់ពុំដាច់ អ្នកលក់ក៏បានបញ្ចុះតម្លៃ20%វិញនៅថ្ងៃទិវានៃសេចក្តីស្រឡាញ់ ហើយក៏ត្រូវបានបុរសម្នាក់ទិញយកទៅក្នុងតម្លៃ43.2$។ រកតម្លៃដើមបំផុតរបស់តុក្កតាខ្លាឃ្មុំនេះ។

**A**. 43.2$ B. 43.5$ C. 45.0$ D. 44.5$ E. ចម្លើយផ្សេង

**៣**. ពហុកោណមួយមានផលបូកមុំក្នុងទាំងអស់តូចជាង$2021^o$។ រកចំនួនជ្រុងច្រើនបំផុតនៃពហុកោណនេះ។

A. 5 B. 6 C. 8 D. 10 E. ចម្លើយផ្សេង

**៤**. គេឲ្យសមីការ $x^2-2(m+1)x+4m-9=0$ មានឬសពីរ $\alpha$ និង$\beta$ ។ កំណត់តម្លៃ$_m$ដើម្បីឲ្យ $\alpha^2+\beta^2=2(\alpha+\beta)+17$។

A. $m=-1$ B. $m=0$ C. $m=1$ D. $m=\frac{1}{2}$ E. ចម្លើយផ្សេង

**៥**. ក្នុងថង់មួយមានឃ្លីសរុប27គ្រាប់ដែលក្នុងនោះមានតែឃ្លីពណ៌ក្រហម និងពណ៌ខៀវ។ គេចាប់ឃ្លីមួយគ្រាប់ចេញពីថង់ដោយចៃដន្យ។ រកចំនួនឃ្លីពណ៌ក្រហមដើម្បីឲ្យប្រូបាបដែលចាប់បានឃ្លីពណ៌ខៀវស្មើនឹង$\frac{2}{3}$។

A. 6គ្រាប់ B. 9គ្រាប់ C. 12គ្រាប់ D. 18គ្រាប់ E. ចម្លើយផ្សេង

**៦**. បុរសម្នាក់និយាយការពិតនៅថ្ងៃច័ន្ទ ,ថ្ងៃពុធ និងថ្ងៃសុក្រ ហើយនិយាយកុហកនៅថ្ងៃផ្សេងទៀតប្រចាំសប្តាហ៍។ ថ្ងៃមួយ គាត់និយាយថា "ខ្ញុំនឹងនិយាយការពិតនៅថ្ងៃស្អែក"។ តើបុរសនោះនិយាយឃ្លាខាងលើនៅថ្ងៃណា?

A. ថ្ងៃច័ន្ទ B. ថ្ងៃអង្គារ C. ថ្ងៃអាទិត្យ D. ថ្ងៃព្រហស្បត្តិ៍ E. ចម្លើយផ្សេង

**៧**. ចំនួន2021អាចសរសេរជាផលគុណនៃពីរចំនួនបឋមបាន។ គណនាផលបូកនៃចំនួនបឋមនោះ។

A. 80 B. 89 C. 73 D. 90 E. ចម្លើយផ្សេង

**៨**. គេឲ្យបីចំនួនពិត $a$ ,$b$ និង $c$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $a^2+1=-2b$ ,$b^2+1=2c$ និង$c^2+1=2a$ ។ គណនា $a^{2020}-b^{2021}+c^{2022}$ ។

A. $-1$ B. 0 C. 3 D. 1 E. ចម្លើយផ្សេង

**៩**. គេឲ្យជាបីចំនួនពិត $a,b$ និង $c$ ខុសពីសូន្យ។ ចូរកំណត់តម្លៃដែលអាចមាននៃកន្សោម $\frac{a}{|a|}+\frac{b}{|b|}+\frac{c}{|c|}$ ។

A. $3,-3$ B. $-1,1$ C. $-1,0,1$ D. $-3,0,3$ E. ចម្លើយផ្សេង

**១០**. គេឲ្យ $7^{2x}=36$ និង $7^{-x}=6^{-\frac{a}{2}}$ ។ តម្លៃនៃ a គឺ

A.1 B.2 C.3 D.4 E. ចម្លើយផ្សេង

**១១**. គេឲ្យ $1-\frac{4}{x}+\frac{4}{x^2}=0$ និង $A=\frac{x}{2}$ ។ តម្លៃនៃ A គឺ

A.0 B.1 C.2 D.3 E. ចម្លើយផ្សេង

**១២**. $a,b$ គឺជាចំនួនពិតពីរខុសគ្នា ដែល $a^2=6a+8$ , $b^2=6b+8$ ។ គណនា $\left(\frac{4}{a}\right)^2+\left(\frac{4}{b}\right)^2$

A.5 B.7 C.9 D.13 E. ចម្លើយផ្សេង

**១៣**. គេឲ្យផ្នែកទសភាគនៃ $5+\sqrt{11}$ គឺ A ហើយ $5-\sqrt{11}$ គឺ B ។ តាង $C=A+B$ នោះតម្លៃនៃ C គឺ

A.1 B.2 C.3 D.0 E. ចម្លើយផ្សេង

**១៤**. គណនាតម្លៃនៃ $0.125^{2016}\times(2^{2017})^3$

A.1 B.8 C.10 D.16 E. ចម្លើយផ្សេង

**១៥**. គណនាផលបូក $P=\frac{1+100^4+101^4}{1+100^2+101^2}$

A.10101 B.10000 C.11001 D.10100 E. ចម្លើយផ្សេង